ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ : ៤៧១ អយក.ប្រក

# ប្រកាស

## ស្តីពី ការបើកសាលាបឋមសិក្សា ត្រពាំងកក់ក្តួច ជាឧបសម្ព័ន្ធរបស់ សាលាបឋមសិក្សា ក្ងួនសត្វ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ៨១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលចំណងជើងនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ត្រពាំងកក់ក្តួច ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០២ ដោយមានចំណារឯកភាពរបស់មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត កំពត ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

## សំរេច

**ប្រការ១** : បើកសាលាបឋមសិក្សាត្រពាំងកក់ក្តួច ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា ក្ងួនសត្វ ដែលមានទីតាំងស្ថិតនៅភូមិ ចុងព្រៀញ ឃុំ ក្ងួនសត្វ ស្រុក កំពត ខេត្ត កំពត ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា ត្រពាំងកក់ក្តួច ត្រូវមានប្រធានក្រុមម្នាក់ ទទួលខុសត្រូវ រួមជាមួយនាយកសាលាបឋមសិក្សា ក្ងួនសត្វ ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក កំពត នាយកសាលាបឋមសិក្សា ក្ងួនសត្វ និង ប្រធានក្រុមសាលាឧបសម្ព័ន្ធ ត្រពាំងកក់ក្តួច មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត កំពត

**ដើម្បីជូនជ្រាបជាពត៌មាន**

-ដូចប្រការ ៣

-កាលប្បវត្តិ-ឯកសារ នា .បស